ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ១០៩៧ មស.ក្រខ

ថ្ងៃពុធ ០១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០១៩

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ ៖** ស្តីពីការផ្តល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៩។

**យោង ៖**
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ១១៥៧៧ សហវ.អថ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ៩៦២៦ សហវ.អថ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- របាយការណ៍ស្តីពីផែនការក្របខណ្ឌឆ្នាំ២០១៩ របស់ក្រសួង ស្ថាប័ន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានយល់ព្រមផ្តល់ជាគោលការណ៍ជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិលចំនួន **៥,៩៩៦កន្លែង** មន្ត្រីជាប់កិច្ចសន្យាចំនួន **១៨,២៩២នាក់** និងគ្រូបង្រៀនជាប់កិច្ចសន្យាចំនួន **៧,៩៩៦នាក់** គ្រូបង្រៀនពីរថ្នាក់ពីរពេលចំនួន **១២,៨៩៧នាក់** គ្រូបង្រៀនថ្នាក់គួប២ ចំនួន **២,៥៩៨នាក់** គ្រូបង្រៀនថ្នាក់គួប៣ចំនួន **១២០នាក់** គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធចំនួន **២,៤៧២នាក់** និងគ្រូបង្រៀនជាប់កិច្ចសន្យាខ្មែរឥស្លាមចំនួន **១៧៨នាក់** ដើម្បីផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ដូចមានខាងក្រោម៖

| **ល.រ** | **ក្រសួង ស្ថាប័ន** | **ផែនការក្របខណ្ឌឆ្នាំ២០១៩** | | | |
|---|---|---|---|---|---|
| | | ក្របខណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា | ឆ្មាំទំនប់ប្រព័ន្ធជារាសាស្ត្រ |
| ១ | ព្រះបរមរាជវាំង | ០៩ | ២៥០ | | |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ២១ | ១១២ | | |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១៦ | ៥២ | | |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០០ | ១៤៣ | | |
| ៥ | មហាផ្ទៃ (ទីស្តីការក្រសួង) | ២០ | ៧៩ | | |
| ៥.១ | មហាផ្ទៃ (រដ្ឋបាលថ្នាក់ក្រោមជាតិ) | ២៤៩ | ១៣០៥ | | |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិង | ០៦ | ២៥០ | | |



ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

| ល.រ | ក្រសួង ស្ថាប័ន | ផែនការក្របខណ្ឌឆ្នាំ២០១៩ | | | |
|---|---|---|---|---|---|
| | | ក្របខណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា | ផ្ទាំទំនប់ប្រព័ន្ធធារាសាស្ត្រ |
| | អធិការកិច្ច | | | | |
| ៧ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១១ | ១០០ | | |
| ៨ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១២១ | ៤៧៥ | | |
| ៩ | ព័ត៌មាន | ២៤ | ៧១៥ | | |
| ១០ | សុខាភិបាល | ១៣០០ | ៣៥៦៨ | | |
| ១១ | រ៉ែនិងថាមពល | ១១ | ២០០ | | |
| ១២ | ផែនការ | ០០ | ១២៥ | | |
| ១៣ | ពាណិជ្ជកម្ម | ២០ | ២០១ | | |
| ១៤ | អប់រំ យុវជន និងកីឡា | ៣៦០០ | ៦៥៧ | | |
| ១៥ | កសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ១២០ | ១០២៤ | | |
| ១៦ | វប្បធម៌និងវិចិត្រសិល្បៈ | ៩២ | ៨០៩ | | |
| ១៧ | បរិស្ថាន | ៤៧ | ៣៥៥ | | |
| ១៨ | អភិវឌ្ឍន៍ជនបទ | ០០ | ៨៧ | | |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០០ | ៤៤៧ | | |
| ២០ | ប្រៃសណីយ៍និងទូរគមនាគមន៍ | ៣០ | ១២៦ | | |
| ២១ | ធម្មការនិងសាសនា | ០០ | ៥១៦ | | |
| ២១.១ | អគ្គាធិការដ្ឋានពុទ្ធិកសិក្សា | ០០ | | ១៤៦២ | |
| ២២ | កិច្ចការនារី | ៤០ | ៤១០ | | |
| ២៣ | សាធារណការនិងដឹកជញ្ជូន | ១២១ | ១៥៥០ | | |
| ២៤ | យុត្តិធម៌ | ០០ | ៦២ | | |
| ២៤.១ | អគ្គនាយកដ្ឋានកិច្ចការតុលាការ | ០០ | ៤៧០ | | |
| ២៥ | ទេសចរណ៍ | ១៥ | ៥២៩ | | |
| ២៦ | រៀបចំដែនដី នគរូបនីយកម្ម | ៤៧ | ៣២៣ | | |
| ២៧ | ធនធានទឹក និងឧតុនិយម | ២៧ | ៤៤៥ | | ២៥០ |
| ២៧.១ | អាជ្ញាធរទន្លេសាប | ០០ | ២៩ | | |
| ២៧.២ | គណៈកម្មការជាតិទន្លេមេគង្គកម្ពុជា | ០០ | ១៥ | | |
| ២៨ | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៤ | ៣៨៨ | | |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ០០ | ១៩០ | | |
| ៣០ | មុខងារសាធារណៈ | ០៦ | ២៩៨ | | |
| ៣១ | ឧស្សាហកម្មនិងសិប្បកម្ម | ២៧ | ២០០ | | |
| ៣២ | គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម | ០២ | ៧៥ | | |
| សរុប | | ៥៩៩៦ | ១៦៥៨០ | ១៤៦២ | ២៥០ |

យោងតាមចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដូចមានយោងខាងលើ ក្រសួងមុខងារសាធារណៈ សូមគោរពស្នើគ្រប់ក្រសួង ស្ថាប័ន មេត្តាសហការអនុវត្តនូវគោលការណ៍មួយចំនួនដូចខាងក្រោម៖

១. វិធានការចំពោះការជ្រើសរើសនិងការប្រើប្រាស់ធនធានមនុស្សឆ្នាំ២០១៩

១.១ ការជ្រើសរើសដោយការប្រឡងប្រជែងពីក្នុងចំណោមសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល

ក្រសួង ស្ថាប័ន ត្រូវធ្វើការប្រកាសជ្រើសរើសចេញពីការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ក្នុងពេលតែមួយ និងត្រូវប្រកាសលទ្ធផលប្រឡងជាប់ស្ថាពរយ៉ាងយូរត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០១៩ ព្រមទាំងចាត់ចែងរៀបចំបើកផ្តល់បៀវត្សដល់បេក្ខជនប្រឡងជាប់ឱ្យបានយ៉ាងយូរ ០១ខែ ក្រោយការទទួលស្គាល់លទ្ធផលពីក្រសួងមុខងារសាធារណៈ។

ចំពោះការជ្រើសរើសក្របខណ្ឌរបស់ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងសុខាភិបាល ត្រូវបានកំណត់ដោយលិខិតជូនដំណឹងរបស់ក្រសួងមុខងារសាធារណៈ ដែលមានគោលការណ៍ដោយឡែក។

១.២ ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូបង្រៀនប្រភេទផ្សេងទៀត របស់ក្រសួងអប់រំ យុវជននិងកីឡា

ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូបង្រៀនប្រភេទផ្សេងទៀត របស់ក្រសួងអប់រំ យុវជននិងកីឡា ដែលត្រូវបានអនុញ្ញាត ជាគោលការណ៍ដោយរាជរដ្ឋាភិបាល ត្រូវអនុវត្តតាមលក្ខខណ្ឌ បែបបទ និងនីតិវិធីជាធរមាន។

ចំពោះប្រាក់កម្រៃ និងការបើកផ្តល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូបង្រៀនប្រភេទផ្សេងទៀត ត្រូវរៀបចំទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា គ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងរំលឹកប្រាក់កម្រៃតាមចំនួនខែដែលបានប្រើប្រាស់ជាក់ស្តែង និងពិនិត្យលទ្ធភាពក្នុងការបើកផ្តល់ប្រាក់កម្រៃរៀងរាល់ពីរសប្តាហ៍ម្តង តាមសារាចរណែនាំលេខ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការអនុវត្តនីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា នៅពេលបើកឱ្យមានការប្រឡងប្រជែងសូមមេត្តារៀបចំជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យចូលបម្រើការងារ ដើម្បីបំពេញមុខតំណែងដែលទំនេរ និងសេចក្តីត្រូវការដែលមានពិតប្រាកដនៅតាមអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងមន្ទីរអង្គភាពជំនាញរាជធានី ខេត្ត ព្រមទាំងយកចិត្តទុកដាក់ដល់បេក្ខភាពជាជនពិការដែលមានសមត្ថភាពសមស្រប ២% នៃចំនួនក្របខណ្ឌសរុបរបស់សាមីក្រសួង ស្ថាប័ន ហើយត្រូវមានបេក្ខនារីជាប់ជាស្ថាពរពី ២០% ទៅ ៥០% នៃចំនួនក្របខណ្ឌដែលទទួលបានប្រចាំឆ្នាំ។

សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន មេត្តារៀបចំស្នើសុំមន្ត្រីតំណាងក្រសួងមុខងារសាធារណៈ ចូលរួមក្នុងដំណើរការប្រឡងឱ្យបានមុនពេលរៀបចំបង្កើតគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសប្រចាំឆ្នាំ ដើម្បីក្រសួងមុខងារសាធារណៈ មានលទ្ធភាពចូលរួមសហការចាប់តាំងពីដំណាក់កាលដំបូង។

សូមសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូនៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
" ដើម្បីជូនជ្រាប "
-នាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌនៃក្រសួងមុខងារសាធារណៈ
-មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត
" ដើម្បីសហការអនុវត្ត "
-ឯកសារ កាលប្បវត្តិ